ព្រឹត្តប័ត្រព័ត៌មានសង្ខេប

សប្តាហ៍ដែលបញ្ចប់
ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺះ

- ប្រទេសកម្ពុជា និងវៀតណាមពិភាក្សាអំពីឱកាសពាណិជ្ជកម្មដែលអាចធ្វើបានតាមរយៈច្រកទ្វារព្រំដែនដែលទើបនឹងបើកថ្មី
- ប្រទេសថៃនឹងផ្តល់ថវិកាចំនួន ១,៦ប៊ីលានដុល្លារ ដល់ប្រជាជនក្រីក្រ និងវិស័យទេសចរណ៍ ក្នុងច្បាប់លើកញ្ចប់ថវិកាបម្រុងសម្រាប់ជួយជំរុញសេដ្ឋកិច្ចនៅពេលជួបវិបត្តិ (Stimulus bill)
- លោកប្រធានាធិបតី ដូណាល់ត្រាំ ពន្យារការដាក់ពន្ធគយដើម្បីផ្តល់លទ្ធភាពដល់អ្នកទិញទំនិញក្នុងអំឡុងពេលបុណ្យណូអែល

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះគឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗនៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារបណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីអោយការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះមានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តន៍នៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ប្រទេសកម្ពុជា និងវៀតណាមពិភាក្សាអំពីឱកាសពាណិជ្ជកម្មដែលអាចធ្វើបានតាមរយៈច្រកទ្វារព្រំដែនដែលទើបបើកថ្មី

មន្ត្រីជំនាញរបស់កម្ពុជា និងវៀតណាមបានជួបពិភាក្សាគ្នានៅសប្តាហ៍នេះ ដើម្បីពិភាក្សាទៅលើឱកាសបង្កើនពាណិជ្ជកម្មតាមរយៈច្រកទ្វារព្រំដែន បន្ទាយចក្រី ដែលបានបើកដំណើរការកាលពីខែឧសភា កន្លងទៅនេះ នៅខេត្តព្រៃវែង។

កន្លងមក មានច្រករបៀងផ្លូវទឹកតែមួយគត់ដែលពាណិជ្ជករកម្ពុជាអាចនាំចេញដោយផ្ទាល់បាន ដែលភាគច្រើនគឺនាំចេញអង្ករ និងផ្លែស្វាយ ទៅកាន់ប្រទេសវៀតណាម។

យោងតាមអាជ្ញាធរ ដុង ថាប (Dong Thap) ក្នុងរយៈពេល ៧ខែដំបូងនៃឆ្នាំនេះ ពាណិជ្ជកម្មនៅច្រកព្រំដែនមានទំហំទឹកប្រាក់ប្រមាណ ៥៥លានដុល្លារអាមេរិក។

កាលពីឆ្នាំមុន ការធ្វើពាណិជ្ជកម្មជារួមរវាងប្រទេសទាំងពីរមានចំនួន ២,៧ ប៊ីលានដុល្លារ ក្នុងនោះ ប្រទេសកម្ពុជាបាននាំចេញទំនិញ និងសេវាកម្ម ដែលមានចំនួន ៣៦២លានដុល្លារ រីឯការនាំចូលមានចំនួន ២,៣២ ប៊ីលានដុល្លារ។ ក្នុងត្រីមាសទី១នៃឆ្នាំនេះ ប្រទេសកម្ពុជាបានធ្វើការនាំចេញទៅកាន់ប្រទេសវៀតណាមក្នុងទំហំទឹកប្រាក់ប្រមាណ ៧៥លានដុល្លារ និងនាំចូលប្រមាណ ៦២៣ លានដុល្លារ។

## តារាងប្រចាំសប្តាហ៍៖ ការនាំចេញរបស់ប្រទេសកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ ក្នុងត្រីមាសទី១ ឆ្នាំ ២០១៩

របាយការណ៍ប្រចាំសប្តាហ៍នេះបង្ហាញថាការនាំចេញរបស់កម្ពុជាទៅកាន់អាមេរិក បានកើនឡើងខ្ពស់ដល់ ៣៥,៤% នៅក្នុងត្រីមាសទី១នៃឆ្នាំ២០១៩ បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨។ ជាលទ្ធផលសរុប ការនាំចេញទៅដៃគូរពាណិជ្ជកម្មទាំងអស់របស់កម្ពុជា មានការកើនឡើងចំនួន ១៣,៣%។ ការនាំចេញរបស់កម្ពុជាភាគច្រើនជាសំលៀកបំពាក់ ស្បែកជើង និងផលិតផលឧស្សាហកម្មផ្សេងៗ។

ការកើនឡើងនៃការនាំចេញទៅកាន់សហរដ្ឋអាមេរិកអាចបណ្តាលមកពីសង្គ្រាមពាណិជ្ជកម្ម រវាងអាមេរិក និងចិន ដោយត្រាប្តូរប្រាក់រៀលកម្ពុជា ត្រូវបានភ្ជាប់ (pegged) ទៅនឹងប្រាក់ដុល្លារ (លប់បំបាត់ការគិតគូពីបញ្ហាអត្រាប្តូរប្រាក់) ហើយពាណិជ្ជកម្មជាមួយដៃគូដ៏ទៃទៀត ក៏បានកើនឡើងដូចការរំពឹងទុកដែរ។

បច្ចុប្បន្ននេះ យើងមិនទាន់អាចដឹងទេថាតើសកម្មភាពនាំចេញដែលកើនឡើងនេះ ផ្តល់លទ្ធផលអ្វីខ្លះដល់ផលិតផលសេដ្ឋកិច្ចពិតប្រាកដ ឬក៏គ្រាន់តែជាការប្តូរទីតាំងរបស់ក្រុមហ៊ុនចិន ក្នុងការនាំចេញផលិតផលរបស់ខ្លួន តាមរយៈប្រទេសកម្ពុជា ដើម្បីគេចវេសពីពន្ធគយរបស់សហរដ្ឋអាមេរិក ឬយ៉ាងណានោះទេ។

### ការនាំចេញរបស់ប្រទេសកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ ក្នុងត្រីមាសទី១ ឆ្នាំ២០១៩




ប្រភព៖ [ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០១៩]

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ប្រទេសថៃនឹងផ្តល់ថវិកាចំនួន ១,៦ប៊ីលានដុល្លារ ដល់ប្រជាជនក្រីក្រ និងវិស័យទេសចរណ៍ ក្នុងច្បាប់លើកញ្ជប់ថវិកាបម្រុងសម្រាប់ជំរុញសេដ្ឋកិច្ចនៅពេលជួបវិបត្តិ (Stimulus bill)

រាជរដ្ឋាភិបាលនៃប្រទេសថៃ [បានគ្រោងនឹងចំណាយថវិកា] ចំនួន ១,៦ប៊ីលានដុល្លារអាមេរិក ដើម្បីជំរុញសេដ្ឋកិច្ចដោយផ្តល់សាច់ប្រាក់ចំនួន ១ ០០០បាត ដល់ប្រជាជនក្រីក្រដែលបានចុះបញ្ជី និង ១ ៥០០បាត ដល់ប្រជាពលរដ្ឋទាំងឡាយណាដែលចង់ធ្វើដំណើរទៅខេត្តផ្សេងៗនៅក្នុងប្រទេសថៃ។

រាជរដ្ឋាភិបាលក៏បានគ្រោងចំណាយ ១៩ប៊ីលានបាតផងដែរ ដើម្បីជួយដល់កសិករ និងសហគ្រាសធុនតូច និង មធ្យម ព្រមទាំងវិធានការផ្តល់ឧបត្ថម្ភធនលើការទូទាត់ការប្រាក់សម្រាប់សហគ្រាសធុនតូច និងមធ្យម។

រាជរដ្ឋាភិបាលរំពឹងថា កញ្ចប់ថវិកានេះនឹងអាចជួយជំរុញសេដ្ឋកិច្ចអោយមានកំណើនដល់ ៣,៥%នៅឆ្នាំនេះ។

## សេដ្ឋកិច្ចពិភពលោក

### លោកប្រធានាធិបតី ដូណាល់ត្រាំ ពន្យារការដាក់ពន្ធដើម្បីផ្តល់លទ្ធភាពដល់អ្នកទិញទំនិញក្នុងអំឡុងពេលបុណ្យណូអែល

លោកប្រធានាធិបតីអាមេរិក ដូណាល់ត្រាំ បានពន្យាពេលដំឡើងពន្ធ ១០%លើទំនិញដែលផលិតនៅប្រទេសចិន ដែលជាប្រភេទទំនិញសម្រាប់អំណោយណូអែលដែលពេញនិយម រួមមាន៖ ទូរស័ព្ទដៃ កុំព្យូទ័រយួរដៃ វីដេអូហ្គេម ឧបករណ៍ក្មេងលេង ស្បែកជើង និងសំលៀកបំពាក់។ ការដំឡើងនេះនឹងត្រូវអនុវត្តនៅថ្ងៃទី ១៥ ខែធ្នូ ជំនួសវិញ។

ការប្រកាសរបស់តំណាងពាណិជ្ជកម្មអាមេរិក ក៏បានរួមបញ្ចូលផងដែរនូវ បញ្ជីលើកលែងពន្ធទៅលើផលិតផលមួយចំនួនដែលទាក់ទងនឹងសុខភាព សុវត្ថិភាព និងសន្តិសុខជាតិ។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមាន៖ អតិផរណានៅក្នុងប្រទេស ជប៉ុន សឹង្ហបុរី និងការសម្រេចចិត្តលើអត្រាការប្រាក់ របស់ប្រទេសឥណ្ឌូនេស៊ី និងអូស្ត្រាលី។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

<u>ថ្ងៃចន្ទ ទី១៩ ខែសីហា</u>

- តុល្យភាពពាណិជ្ជកម្មរបស់ជប៉ុន សម្រាប់ខែកក្កដា
- អត្រាអតិផរណានៅតំបន់អឺរ៉ុប សម្រាប់ខែកក្កដា
- កំណើនផ.ស.ស. របស់ ថៃ សម្រាប់ត្រីមាសទី២ ឆ្នាំ២០១៩
- អត្រានិកម្មភាពរបស់ហុងកុង សម្រាប់ខែកក្កដា

<u>ថ្ងៃអង្គារ ទី២០ ខែសីហា</u>

- ការសម្រេចចិត្តលើអត្រាការប្រាក់របស់ អូស្ត្រាលី
- លទ្ធផលនៃការសាងសង់នៅតំបន់អឺរ៉ុប សម្រាប់ខែមិថុនា

<u>ថ្ងៃពុធ ទី២១ ខែសីហា</u>

- សន្ទស្សន៍ ថ្លៃផលិតរបស់កូរ៉េខាងត្បូង សម្រាប់ខែកក្កដា
- តុល្យភាពពាណិជ្ជកម្មរបស់ ថៃ សម្រាប់ខែកក្កដា
- សន្ទស្សន៏នៃថ្លៃលក់រាយរបស់ហ្វីលីពីន សម្រាប់ខែមិថុនា
- ការលក់ឡាននៅឥណ្ឌូនេស៊ី សម្រាប់ខែកក្កដា

<u>ថ្ងៃព្រហស្បត្តិ៍ ទី ២២ ខែសីហា</u>

- សន្ទស្សន៍សកម្មភាពឧស្សាហកម្មទាំងអស់ នៅជប៉ុន សម្រាប់ខែមិថុនា
- ការសម្រេចចិត្តនៃអត្រាការប្រាក់របស់ ឥណ្ឌូនេស៊ី
- ការលក់ឡានថ្មីរបស់ថៃ សម្រាប់ខែកក្កដា
- អត្រានិកម្មភាពនៅតៃវ៉ាន់ សម្រាប់ខែកក្កដា

<u>ថ្ងៃសុក្រ ទី ២៣ ខែសីហា</u>

- អត្រាអតិផរណារបស់ជប៉ុន សម្រាប់ខែកក្កដា
- សន្ទស្សន៍នាំមុខរបស់ ម៉ាឡេស៊ី សម្រាប់ខែមិថុនា
- អតិផរណារបស់សឹង្ហបុរី សម្រាប់ខែកក្កដា
- ផលិតកម្មឧស្សាហកម្មរបស់តៃវ៉ាន់ សម្រាប់ខែ កក្កដា